ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មករា ២០០៦ / January 2006

កញ្ញា អ៊ុច ចំន្ទតារានី / **Ms. Ouch Chandarany**

លោកស្រី ប៉ុន ឌូរីណា / **Ms. Pon Dorina**

លោក ហ៊ីង វុត្ថា / **Mr. Hing Vutha**

លោក ភឹម រុនស៊ីណារិទ្ធិ / **Mr. Phim Runsinarith**

បកប្រែដោយៈ **យូ សិទ្ធីរិទ្ធ**

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា
# Main Economic Activities of Cambodia

នៅត្រីមាសទី៣ ២០០៥ ទុនសរុប ៥៦,៥លានដុល្លារ (១៧ គំរោង) បានវិនិយោគក្នុងវិស័យកាត់ដេរ (១៤% នៃវិនិយោគសរុបគិតជាទ្រព្យសកម្មជាប់លាប់) ។ ចិន តៃវ៉ាន់ កម្ពុជា គឺជាវិនិយោគិនធំៗបំផុត ។ ទុនវិនិយោគដែលបានអនុម័តសំរាប់វិស័យកាត់ដេរ កើនឡើងទ្វេដង ពីកំរិត ២៣,២លានដុល្លារ (១២គំរោង) នៅត្រីមាសមុន ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន វាកើនបាន ២៨,៤% ។

In the third quarter of 2005, a total of $56.5 million (17 projects) was invested in the garment sector, accounting for 14 percent of total investments in fixed assets during this quarter. China, Taiwan and Cambodia were the top three investors. Fixed asset approvals in the garment sector more than doubled from $23.2 million (12 projects) the preceding quarter. Compared to the same quarter last year, it rose by 28.4 percent.

**Fixed Asset Investments Approved by the CDC for Garment Sector**
(US$ million)




*Note: Latest data available are for September 2005.*
Including expansion project approvals.
Source: Council for the Development of Cambodia

នៅខែតុលា ២០០៥ មានភ្ញៀវបរទេស ៧១.៩០៧នាក់ មកដល់កម្ពុជាតាមជើងហោះហើរអន្តរជាតិ តាមច្រកអាកាសយានដ្ឋាននៅភ្នំពេញ និង សៀមរាប (មានកំនើន ២២% ធៀបនឹងខែមុន និង ៣៩,៦% ខ្ពស់ជាងខែតុលា ២០០៤) ។ នៅអាកាសយានដ្ឋានសៀមរាប ទទួលបានភ្ញៀវចំនួន ៣៧.៤៩១នាក់ រីឯអាកាសយានដ្ឋានក្រុងភ្នំពេញ ទទួលបានភ្ញៀវចំនួន ៣៤.៤១៦ នាក់ ។

In October 2005, Cambodia received 71,907 foreign visitors by international flights at both Phnom Penh and Siem Reap, an increase of 22 percent compared to the preceding month, and 39.6 percent more than in October 2004. Siem Reap airport welcomed 37,491 foreign visitors, while Phnom Penh airport received 34,416 arrivals.

**Foreign Visitor Arrivals to Cambodia by International Flights**
(thousand persons)




*Note: Latest data available are for October 2005.*
Source: Ministry of Tourism

តំលៃគំរោងសាងសង់ដែលបានអនុម័តនៅភ្នំពេញ ធ្លាក់ចុះដល់ ១៤,៨លានដុល្លារនៅខែតុលា ២០០៥ ធៀបនឹង ១៩,១លានដុល្លារនៅខែកញ្ញា និង ១៥,៦លានដុល្លារនៅខែតុលា ២០០៤ ។ តំលៃគំរោងសាងសង់ផ្ទះល្វែងបានធ្លាក់ចុះដល់ ៤,២លានដុល្លារ ធៀបនឹង ១៣,៧លានដុល្លារនៅខែមុន ។ តំលៃគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ ក៏ធ្លាក់ចុះពីកំរិត ៣,៦លានដុល្លារដល់ ០,៥លានដុល្លារ រីឯសំណង់ឯទៀតកើនជាងប្រាំដងដល់ ១០,១លានដុល្លារ ។

The value of construction project approvals in Phnom Penh declined to $14.8 million in October 2005, down from $19.1 million in September, and from $15.6 million in October 2004. The value of flat construction projects dropped to $4.2 million, down from $13.7 million in the preceding month. The value of villa and house construction approvals also decreased – from $3.6 million to $0.5 million. However, other construction projects increased more than five times, reaching $10.1 million.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for October 2005.*
Source: Department of Cadastre and Geography, Phnom Penh Municipality.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែធ្នូ ថ្លៃប្រេងសាំង និងម៉ាស៊ូតនៅភ្នំពេញ ថយចុះបើធៀបនឹងខែមុន ។ ថ្លៃសាំងជាមធ្យមនៅលើទីផ្សារគឺ ៣.៧១៤រៀល/លីត្រ នៅខែធ្នូ (ចុះពី ៣.៧៦៨រៀល ក្នុងមួយលីត្រ នៅខែវិច្ឆិកា) ហើយម៉ាស៊ូតលក់ថ្លៃ ២.៨៨១រៀល ក្នុងមួយលីត្រ (ចុះពី ២.៩៣២រៀល/លីត្រ នៅខែវិច្ឆិកា) ។

Gasoline and diesel prices in Phnom Penh fell in December from the preceding month. The average market price of gasoline was 3,714 riels/litre in December (down from 3,768 riels/litre in November) and diesel was 2,881 riels/litre (down from 2,932 riels/litre in November).

**Price of Gasoline and Diesel Oil in Phnom Penh**

(Riels per litre)




Sources: CDRI and National Institute of Statistics

នៅខែវិច្ឆិកា ថ្លៃទំនិញប្រើប្រាស់ទូទៅនៅភ្នំពេញធ្លាក់ចុះតិចតួចអស់ 0,១% ធៀបនឹងខែតុលា ។ នៅកំឡុងពេលនេះ ថ្លៃផលិតផលថែទាំ និងសំអាងកាយថយចុះ ២,៨% បន្ទាប់មកគឺ ការដឹកជញ្ជូន និងទូរគមនាគមន៍ (0,៨៥%) សំលៀកបំពាក់/ស្បែកជើង (0,៥%) និងម្ហូបអាហារ (0,១៨%) ប៉ុន្តែ ថ្លៃទំនិញផ្សេងទៀត សឹងគ្មានការប្រែប្រួល ។ ធៀបនឹងខែវិច្ឆិកា ២00៤ ថ្លៃទំនិញប្រើប្រាស់ទូទៅ កើនឡើង ៦,៦% ។

In November, overall consumer prices in Phnom Penh declined slightly, by 0.1 percent, from October. Prices of personal care products, transportation and communication, clothing and footwear, and foods fell during this period, while prices of other major items remained almost unchanged. The prices of personal care products declined by 2.8 percent, followed by the cost of transportation and communication (0.85 percent), clothing and footwear (0.5 percent), and foods (0.18 percent). Compared to November 2004, the overall consumer prices have increased by 6.6 percent.

**Consumer Price Index**

(July–December 2000=100)




*Note: Latest data available are for November 2005*

Source: National Institute of Statistics

នៅត្រីមាសទី៣ ២00៥ ថ្លៃមាសជាមធ្យមនៅទីផ្សារភ្នំពេញ កើនដល់ ៥៥,៤0ដុល្លារក្នុងមួយជី រឺកើន ៥,៥% ពីក៏រិត ៥២,៥0ដុល្លារក្នុងមួយជី នៅត្រីមាសទី២ ។ វាកើនឡើងយ៉ាងខ្លាំងដល់ ១៩,៦% បើធៀបនឹងត្រីមាសទី៣ ឆ្នាំមុន (៤៦,៣0ដុល្លារក្នុងមួយជី) ។

The average market price of gold in Phnom Penh reached $55.4 per *chi* in the third quarter of 2005. It rose by 5.5 percent from $52.5 per *chi* in the second quarter. Compared to the third quarter one year earlier, it increased markedly by 19.6 percent from $46.3 per *chi*.

**Gold Price in Phnom Penh**

(US$ per *chi*)




Source: CDRI and MEF

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ
# Exchange Rate and Monetary Developments

នៅខែធ្នូ ប្រាក់រៀលកម្ពុជាបន្តឡើងថ្លៃ ទល់នឹងដុល្លារUS ដល់ ៤.១៣៨,៤ រៀលក្នុងមួយដុល្លារ រឺឡើងថ្លៃ ១,១% បើធៀបនឹងខែវិច្ឆិកា ។ នៅខែធ្នូ ប្រាក់រៀល ឡើងថ្លៃលឿនជាងនៅខែមុន (ឡើងថ្លៃ 0,៥%) ប៉ុន្តែ ធ្លាក់ថ្លៃ អស់ ២,៧% បើធៀបនឹងខែធ្នូ ២00៤ ។

In December, the Cambodia riel continued to gain value against the US dollar – increasing by 1.1 percent to 4,138.4 riels/dollar, compared to November. The riel appreciation in December was faster than the previous month (0.5 percent). Compared to December 2004, however, the riel depreciated by 2.7 percent.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

ប្រាក់រៀលបន្តឡើងថ្លៃ ទល់នឹងប្រាក់ដុងវៀតណាម និងប្រាក់បាតថៃ នៅខែធ្នូ ដោយប្តូរបានជាមធ្យម ២៥,៩ រៀលក្នុងមួយ១00ដុង (ឡើងថ្លៃ ១,៥% ពីខែវិច្ឆិកា) និង ១00,៦រៀលក្នុងមួយបាត (ឡើងថ្លៃ ១,៣%) ។

Against both the Vietnamese dong and the Thai baht, the Cambodia riel continued to appreciate in December. The riel traded at an average of 25.9 riels per 100 dong in December, an appreciation of 1.5 percent from November. During the same period, the exchange rate between the riel and the Thai baht averaged 100.6 riels/baht, a 1.3 percent appreciation.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

រូបិយវត្ថុទូទៅ ថយចុះ 0,៦% ពីកំរិត ៤.៩៩៣,៨ពាន់លានរៀល នៅខែវិច្ឆិកា ដល់ ៤.៩៦៥,៤ពាន់លានរៀល នៅខែតុលា ក្នុងនេះចំណែកជាប្រាក់រៀល ថយចុះ ១,៤% ដល់ ១.៣៧៨,៣ពាន់លានរៀល និងចំណែកជារូបិយវត្ថុបរទេស ថយចុះ 0,៥% ដល់ ៣.៥៨៧,១ពាន់លានរៀល ។ ដោយឡែកប្រាក់រៀលនៅក្រៅធនាគារ ថយចុះ ១% ដល់ ១.២២២,៦ ពាន់លានរៀល និងប្រាក់រៀលផ្ញើនៅធនាគារ ថយចុះ ៤,២% ដល់ ១៥៥,៧ពាន់លានរៀល ។

Total liquidity declined 0.6 percent from 4,993.8 billion riels in September to 4,965.4 billion riels in October. Both the riel and foreign currency deposits declined simultaneously during this period. The riel declined by 1.4 percent to 1,378.3 billion riels, and foreign currency deposits declined by 0.5 percent to $856.9 million, or 3,587.1 billion riels. Of this, there was a decrease of 1 percent to 1,222.6 billion riels in riels outside banks, and a drop of 4.2 percent to 155.7 billion riels in riel bank deposits.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for October 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស

# External Trade

នៅត្រីមាសទី៣ ២០០៥ ការនាំចេញសរុបរបស់កម្ពុជាមាន ៧៣០លានដុល្លារ ធៀបនឹង ៥១៥លានដុល្លារនៅត្រីមាសទី២ ២០០៥ និង ៦៦៨,៨ លានដុល្លារ នៅត្រីមាសទី៣ ២០០៤ ។ ការនាំចេញទៅ US មាន ៤៩០ លានដុល្លារ នៅត្រីមាសទី៣ កើន ២៤,៦% ពីត្រីមាសដូចគ្នាឆ្នាំមុន ។ នៅកំឡុងពេលដូចគ្នា ការនាំចេញទៅប្រទេសអាស៊ាននៅមានកំរិតទាប រឺប្រហែល ២% នៃការនាំចេញសរុប (១៦,២លានដុល្លារ) ។ ការនាំចេញទៅតំបន់អឺរ៉ុប ថយចុះ ១៩% មកត្រឹម ១៦៣លានដុល្លារ ។

In the third quarter of 2005, Cambodia's total exports amounted to $730 million, compared with around $515 million in the second quarter of 2005 and $668.8 million in the third quarter of 2004. Exports to the United States accounted for $490 million in the third quarter, a 24.6 percent increase from the same quarter one year earlier. During the same period, exports to ASEAN countries remained low, representing around 2 percent of total exports ($16.2 million), but rising by 3.8 percent. However, exports to the EU fell by 19 percent to $163 million during this period.

**Cambodia's Export by Regions**
(US$ million)




Source: Customs and Excise Department

នៅខែតុលា ២០០៥ ការនាំចូលសរុបរបស់កម្ពុជា មានបារី ៣៨,១ពាន់លានរៀល ស៊ីម៉ង់តិ៍ ១០,៦ពាន់លានរៀល និងដែក ៦,១ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៤ ការនាំចូលបារីកើនឡើងជិតបីដង រីឯការនាំចូលស៊ីម៉ង់តិ៍ និងដែកធ្លាក់ចុះ ២,៦% និង១៨,១% រៀងគ្នា ។

Cambodia imported a total of 38.1 billion riels of cigarettes, 10.6 billion riels of cement, and 6.1 billion riels of steel in October 2005. Compared to the same month in 2004, cigarette imports jumped almost threefold, while cement and steel imports dropped by 2.6 percent and 18.1 percent, respectively.

**Imports of Cigarettes and Construction Materials**
(billion riels)




*Note: Latest data available are for October 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

នៅខែតុលា ការនាំចូលប្រេងសាំងកើនបាន ១៨ពាន់លានរៀល និងការនាំចូលម៉ាស៊ូត កើនឡើងជិតដល់ ២០ពាន់លានរៀល ។ បើធៀបនឹងខែដូចគ្នាឆ្នាំមុន ការនាំចូលប្រេងសាំងឡើងទ្វេជាពីរ ផ្ទុយពីការនាំចូលម៉ាស៊ូតដែលបានធ្លាក់ចុះអស់ ៤៩,៤% ។

In October, the value of gasoline imports reached 18 billion riels, and diesel imports amounted to nearly 20 billion riels. Compared to the same month last year, imports of gasoline doubled, in contrast to imports of diesel, which declined by 49.4 percent.

**Imports of Petroleum Products**
(billion riels)




*Note: Latest data available are for October 2005.*
*(Excluding public sector imports)*
Source: Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

មូលនិធិរបស់ឃុំ/សង្កាត់ បានបែងចែកអោយទៅខេត្តកំពង់ធំ ចំនួន ៣,៣៣ ពាន់លានរៀល នៅឆ្នាំ២០០៥ រឺ ១៣,៨% ខ្ពស់ជាងឆ្នាំ២០០៤ ។ ក្នុងនេះ ៦៨% (២,២៦ពាន់លានរៀល) សំរាប់សកម្មភាពអភិវឌ្ឍន៏នៅក្នុង ៨១ឃុំ ហើយ ៣២% ដែលនៅសល់ (១,០៧ពាន់លានរៀល) គឺសំរាប់ប្រតិបត្តិការរដ្ឋបាល ។

Commune/sangkat funds allocated to Kampong Thom Province amounted to about 3.33 billion riels in 2005, 13.8 percent more than in 2004. Of this, 68 percent (2.26 billion riels) was intended for development activities in 81 communes in the province. The remaining 32 percent (1.07 billion riels) was for administrative operations.

**2005 Commune/Sangkat Fund Allocation to Kampong Thom Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ខេត្តស្វាយរៀងដែលនៅជាប់ព្រំប្រទល់វៀតណាម មាន ៨០ឃុំ បានទទួល ៣,០៨ពាន់លានរៀល ពីមូលនិធិឃុំ/សង្កាត់ នៅឆ្នាំ២០០៥ ។ ធៀបនឹងមួយឆ្នាំមុន វាកើនបាន ១៤,២% ។ ខេត្តនេះទទួលបានប្រហែល ២,១១ ពាន់លានរៀល សំរាប់គំរោងអភិវឌ្ឍន៏ និង ០,៩៧ពាន់លានរៀល សំរាប់ចំណាយខាងរដ្ឋបាល ។

Svay Rieng Province, which borders Vietnam and contains 80 communes, received 3.08 billion riels from the commune/sangkat fund in 2005. Compared to one year earlier, it rose by 14.2 percent. The province received around 2.11 billion riels for development projects, and a total of 0.97 billion riels for administration costs.

**2005 Commune/Sangkat Fund Allocation to Svay Rieng Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ខេត្តបន្ទាយមានជ័យ ជាខេត្តជាប់ព្រំប្រទល់ថៃ បានទទួល ២,៩៤ ពាន់លានរៀល ពីមូលនិធិឃុំ/សង្កាត់ក្នុងឆ្នាំ២០០៥ ដោយកើនបាន ១២,៣% ពីឆ្នាំមុន ។ ចំនួនសរុប ២,០២ពាន់លានរៀល បានបែងចែកសំរាប់សកម្មភាពអភិវឌ្ឍន៏ក្នុងខេត្តនេះ ហើយ ០,៩២ពាន់លានរៀលសំរាប់ខាងរដ្ឋបាល ។

Banteay Meanchey, a province bordering Thailand, received 2.94 billion riels from the commune/sangkat fund in 2005, representing an increase of 12.3 percent from last year. A total of 2.02 billion riels was allocated for development activities in this province, and 0.92 billion riels for administration.

**2005 Commune/Sangkat Fund Allocation to Banteay Meanchey Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែកក្កដា-កញ្ញា ២០០៥ ប្រតិបត្តិការថវិកាចរន្តកម្ពុជា មានអតិរេក ៣១ពាន់លានរៀល ធៀបនឹង ២៤៥,៣ពាន់លានរៀល នៅខែមេសា-មិថុនា ។ ការធ្លាក់ចុះយ៉ាងខ្លាំងនូវអតិរេកថវិកាចរន្ត គឺដោយសារការកើនឡើងនៃចំណាយថវិកាចរន្ត ដែលជាទូទៅធ្វើឡើងនៅអំឡុងពេលចុងឆ្នាំ ។ ធៀបនឹងត្រីមាសទី៣ ២០០៤ អតិរេកចរន្ត គឺទាបជាងប្រហែលជាពីរដង ។

Cambodia’s current budget operation showed a surplus of 31 billion riels during July-September 2005, compared with 245.3 billion riels during April-June. The decline in current budget surplus was due to a sharp increase in current budget expenditure, which usually occurs during the end of the year. Compared to the third quarter 2004, the current surplus was about two times lower.

**Current Budget Operations**
(billion riels)




*Note: Provisional for 2004 and Jan-Sept 2005.*
Source: Ministry of Economy and Finance

ចំណូលថវិកាចរន្តមានចំនួន ៦០៩,៨ពាន់លានរៀល នៅត្រីមាសទី ៣ ២០០៥ រឺ ០,៣% ទាបជាងត្រីមាសមុន ។ ក្នុងពេលនេះ ការប្រមូលចំណូលពីពន្ធនាំចេញ-នាំចូល ធ្លាក់ចុះ ៦,៨% ដល់ ២៩៦,៨ពាន់លានរៀល និងពន្ធក្នុងស្រុក ធ្លាក់ចុះ ៥,៥% ដល់ ១៣៩,៥ពាន់លានរៀល ។ ប៉ុន្តែចំណូលមិនមែនពន្ធ កើនឡើង ១៩,២% ដល់ ១៧៣,៥ពាន់លានរៀល ។ ចំណូលចរន្តសរុបកើនបាន ៣៥,៣% ធៀបនឹងត្រីមាសទី៣ ២០០៤ ។

Current budget revenue amounted to 609.8 billion riels in the third quarter of 2005, 0.3 percent lower than in the preceding quarter. During this period, revenue collections from import and export taxes declined by 6.8 percent to 296.8 billion riels, and domestic tax declined by 5.5 percent to 139.5 billion riels. However, revenue from non-tax sources was up 19.2 percent, to 173.5 billion riels. Total current revenue showed an increase of 35.3 percent from the third quarter 2004.

**Current Budget Revenue**
(billion riels)




*Note: Provisional for 2004 and Jan-Sept 2005.*
Source: Ministry of Economy and Finance

ចំណាយថវិកាចរន្តកើនយ៉ាងខ្លាំង បាន ៥៨% ដល់ ៥៧៨,៧ពាន់លានរៀល នៅត្រីមាសទី២ និងទី៣ ២០០៥ ។ ការកើនឡើងនេះ សំខាន់ដោយសារតែការកើនឡើងចំណាយលើរដ្ឋបាលសង្គម (៩៤,៥% ដល់ ២៤១,៦ពាន់លានរៀល) និងចំណាយលើកិច្ចការពារ និងសន្តិសុខជាតិ (៥៨% ដល់ ១១៦,៧ពាន់លានរៀល) ។ ប្រភេទចំណាយ ៣សំខាន់ផ្សេងទៀត (រដ្ឋាបាលទូទៅ សេដ្ឋកិច្ច រដ្ឋបាលផ្សេងៗ) ក៏មានកំណើនគួរសមដែរ ។ ធៀបនឹងត្រីមាសទី៣ ២០០៤ ចំនាយចរន្តបានកើនឡើងប្រហែល ៤៨% ។

Current budget expenditure rose sharply by 58 percent to 578.7 billion riels between the second and third quarters 2005. This increase was primarily led by a rise in expenditures on social administration (94.5 percent to 241.6 billion riels), and defence and security expenditures (58 percent to 116.7 billion riels). Three other major spending categories—general administration, economic administration, and other administration expenditures – also increased moderately. Compared to the third quarter 2004, total current expenditure expanded by about 48 percent.

**Current Budget Expenditure**
(billion riels)




*Note: Provisional for 2004 and Jan-Sept 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា
# Economic Activity of Selected Economic Partners of Cambodia

ក្នុងរយៈពេល ១ឆ្នាំ ដល់ចុងត្រីមាសទី៣ ២០០៥ ផសស ពិតនៅUS កើន ៤,១% ធៀបនឹងអត្រា ៣,៣% នៅចុងត្រីមាសទី២ ដោយបង្ហាញពីការថយចុះតិចជាងមុននៃការវិនិយោគលើស្តុកទំនិញឯកជន និងកំនើនចំណាយប្រើប្រាស់ឯកជន និងចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ ។ ក្នុងរយៈពេលដដែល ផសស ពិត នៅតំបន់អឺរ៉ូ មានកំណើន ១,៥% (0,៦% នៅត្រីមាសមុន) ឯនៅជប៉ុន គឺ២,៩% ។

US real GDP in the year to third quarter 2005 grew at 4.1 percent, accelerating from 3.3 percent in the second quarter 2005. The acceleration in real GDP growth primarily reflected a smaller decrease in private inventory investment and accelerations in private consumption expenditures and in federal government spending. Real GDP of the euro-zone in third quarter 2005 grew by 1.5 percent compared to same quarter of the previous year and by 0.6 percent compared to the previous quarter. Japan GDP grew at 2.9 percent in the year to third quarter 2005.

**GDP Growth Rate by Quarter**
(Percent change over a year earlier)




Source: BEA, Eurostat and OECD

នៅត្រីមាសទី៣ ផសស ចិន មានអត្រាកំនើន ៩,៤% រឺ 0,១% ទាបជាងអត្រានៅត្រីមាសមុន ។ វិស័យឧស្សាហកម្ម មានកំណើនខ្ពស់ដល់ ១១% រីឯវិស័យកសិកម្ម/យករ៉ែ និងសេវាកម្ម មានត្រឹម ៥% និង ៨% រៀងគ្នា ។ ផសស ពិត កូរ៉េខាងត្បូង មានអត្រាកំណើនប្រចាំឆ្នាំ ៤,៤% ឯនៅហុងកុង គឺ ៨,២% ធៀបនឹង ៧,៣% នៅត្រីមាសទី២ ។

China’s GDP in third quarter 2005 grew at 9.4 percent, a 0.1 percent point decline from the growth rate in the last quarter. Secondary industry registered the highest growth at 11 percent, while primary and tertiary industry registered modest growth at 5 percent and 8 percent respectively. The real GDP of South Korea in the third quarter 2005 grew at an annual rate of 4.4 percent. Manufacturing grew by 7 percent led by electric & electronic products including semi-conductors, while the service industry rose by 3.3 percent. Real GDP of Hong Kong grew at 8.2 percent in the third quarter 2005, an increase from 7.3 percent in the second quarter.

**GDP Growth Rate by Quarter**
(Percent change over a year earlier)




Source: National Statistics Department of respective countries

ក្នុងរយៈពេល ១ឆ្នាំដល់ចុងត្រីមាសទី៣ ២០០៥ ផសស ពិត នៅម៉ាឡេស៊ីកើន ៥,៣% (៤,៤% នៅត្រីមាសមុន) ។ នៅថៃ មានកំរិត ៥,៣% (៤,៦% នៅត្រីមាសមុន) ហើយតួលេខដ៏ខ្ពស់នេះ បណ្តាលមកពីកំណើនការនាំចេញ និងទេសចរណ៍ ព្រមទាំងថយចុះការនាំចូល ។ នៅសឹង្ហបុរីមានកំរិត ៧% នៅត្រីមាសទី៣ ធៀបនឹង ៥,៤% នៅត្រីមាសមុន ។

The real GDP of Malaysia in the year to third quarter 2005 grew by 5.3 percent compared to 4.4 percent to the previous quarter. The GDP of Thailand in third quarter 2005 grew at 5.3 percent higher than the 4.6 percent of the previous quarter. This higher growth is mainly due to the surge in exports and expansion of tourism, while imports declined. Singapore's GDP grew at an annual rate of 7 percent in the third quarter 2005 compared with 5.4 percent in the previous quarter.

**GDP Growth Rate by Quarter**
(Percent change over a year earlier)




Source: National Statistics Department of respective countries

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation rates in Selected Economic Partners of Cambodia

ជប៉ុនបន្តមានបរិត្តផរណា ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅ ថយចុះ ០,៧% ក្នុងរយៈពេល ១ឆ្នាំដល់ចុងខែតុលា ដែលជាការថយចុះខ្លាំងបំផុតក្នុងរយៈពេល ៣ឆ្នាំ ។ តាមសារព័ត៌មាន Nikkei រឿងនេះបណ្តាលមកពីការចុះថ្លៃម្ហូបអាហារ ការអប់រំ និងលំហែកំសាន្ត ។ ក្នុងពេលដដែល US មានអត្រាអតិផរណាទំនិញប្រើប្រាស់ចុះដល់ ៤,៣% (៤,៧%នៅខែកញ្ញា) ឯនៅតំបន់អឺរ៉ូ វានៅនឹងត្រឹម ២,៥% ។

Deflation continues in Japan. Its overall consumer price index (CPI) fell by 0.7 percent in the year to October, the biggest drop for three years. According to *Nikkei Shimbun*, this deflation reflected a drop in food prices, lower education fees and a decline in recreation costs. During the same period, the U.S consumer inflation rate edged down to 4.3 percent, from 4.7 percent in September, while the euro area's average inflation rate remained at 2.5 percent.

### Inflation Rate in the US, Europe and Japan

(percentage change over the previous year)




*Note: The latest data available are for Oct 2005.*
Sources: IMF and the *Economist* (Dec, 3-9, 2005)

អតិផរណាក្នុងរយៈពេល ១ឆ្នាំដល់ចុងខែតុលា២០០៥ ឡើងដល់ ១,៨% គឺខ្ពស់ជាងកាលពីខែកញ្ញា បណ្តាលជាសំខាន់មកពីកំណើនថ្លៃឈ្នួលផ្ទះឯកជន និងថ្លៃបន្លែស្រស់ ។ ក្នុងកំឡុងពេលដដែល វាមានការថយចុះដល់ ២,៥% នៅចិន និងឡើងដល់ ១,២% នៅកូរ៉េខាងត្បូង ។

The Hong Kong year-on-year inflation accelerated by 1.8 percent in October 2005. The larger year-on-year increase in the Composite CPI in October 2005 compared to September 2005 was mainly attributable to the increases in private housing rentals as well as the prices of fresh vegetables. During the same period, consumer inflation moderated to 2.5 percent in China and rose to 1.2 percent in South Korea.

### Inflation Rate in China, Hong Kong and S. Korea

(percentage change over the previous year)




*Note: The latest data available are for Oct 2005.*
Sources: IMF and the *Economist* (Dec, 3-9, 2005)

ថ្លៃទំនិញប្រើប្រាស់នៅសឹង្ហបុរីកើន ១,១% នៅខែតុលា ២០០៥ ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសឹង្ហបុរី រឿងនេះបង្ហាញជាសំខាន់មកពី ការឡើងថ្លៃម្ហូបអាហារ សំលៀកបំពាក់ស្បែកជើង ការថែទាំសុខភាព និងការលំហែកំសាន្ត ។ ក្នុងពេលដដែល ថ្លៃទំនិញប្រើប្រាស់ កើន ៣,៣% នៅម៉ាឡេស៊ី និង ៦,២% នៅថៃ ។

The Singapore's consumer price index edged up by 1.1 percent in October 2005 compared to the same month a year ago. According to the Department of Statistics of Singapore, this largely reflected higher costs of food, clothing and footwear, education and stationery, housing, and healthcare, as well as recreation. At the same time, the index rose by 3.3 percent in Malaysia and by 6.2 percent in Thailand in the 12 months to October.

### Inflation Rate in Selected ASEAN Countries

(percentage change over the previous year)




*Note: The latest data available are for Oct 2005.*
Sources: IMF and the *Economist* (Dec, 3-9, 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rate in the World Markets

នៅខែធ្នូ ២០០៥ ដុល្លារUS ចុះថ្លៃទល់នឹងរូបិយវត្ថុចំបងៗភាគច្រើន លើកលែងតែប្រាក់យ៉េនជប៉ុនទេ ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៨៤អឺរ៉ូ/ដុល្លារUS រឺចុះថ្លៃ ០,៦% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េន វាប្តូរបាន ១១៨,៨យ៉េន/ដុល្លារ ធៀបនឹង ១១៨,៤៥យ៉េនកាលពីខែមុន ។ ប្រាក់យ៉េនបន្តចុះថ្លៃ ក្រោយពេលរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលជប៉ុន ពុំមានការបារម្ភអ្វីទេ ចំពោះការចុះថ្លៃប្រាក់យ៉េន ១៥% នៅឆ្នាំនេះ ។

In December 2005, the US dollar lost ground against most major currencies except the Japanese yen. Versus the euro, it traded at 0.84 euro/USD, about a 0.6 percent depreciation from the previous month. Against the yen, it was exchanged at 118.8 JPY/USD from 118.45 a month earlier. The yen continued to weaken after Japan's finance minister and central bank governor signaled that they were comfortable with the yen's 15 percent drop this year.

## Euro and Japanese Yen Against the US Dollar




*Note: Data are up to 26 Dec. 2005*
Sources: The Federal Reserve Bank of New York

នៅខែធ្នូ ២០០៥ ប្រាក់វ៉ុនកូរ៉េខាងត្បូងឡើងថ្លៃ ទល់នឹងដុល្លារUS ដោយប្តូរបាន ១.០២៥,៧៧វ៉ុន/ដុល្លារ ។ ដូចរូបិយវត្ថុឯទៀតដែរ ប្រាក់វ៉ុនឡើងថ្លៃ ដោយសារធនាគារកណ្តាលUS អាចឈប់តំលើងអត្រាការប្រាក់ក្នុងពេលដ៏ខ្លីខាងមុខ និងរបាយការណ៍ពីឱនភាពគណនីចរន្ត US ដ៏ធំនៅខែកក្កដា-កញ្ញា ។ ក្នុងខែនេះដែរ ១ដុល្លារUS ប្តូរបាន ៧,៧៥$ហុងកុង ។

In December 2005, the South Korean won gained in strength against the US dollar, trading at 1,025.77 won per dollar. Like many other currencies, the South Korean won advancement against the US dollar resulted from the signal that Federal Reserve policy makers may soon stop raising U.S rates and the report that the U.S current account deficit in the July-Sept was large. During the same period, the Hong Kong dollar traded at 7.75 against its US counterpart.

## South Korean Won and Hong Kong Dollar Against the US Dollar




Note: Data are up to 26 Dec. 2005
Sources: The Federal Reserve Bank of New York

នៅខែធ្នូ ២០០៥ ដុល្លារសិង្ហបុរីឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ១,៦៧៦ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៦៩៨ដុល្លារសិង្ហបុរី នៅខែវិច្ឆិកា ។ ក្នុងពេលនេះដែរ ប្រាក់បាតថៃប្តូរបាន ៤១,១២បាត/ដុល្លារUS គឺដូចគ្នានឹងខែមុន ។ រូបិយវត្ថុអាស៊ីភាគច្រើនបានឡើងថ្លៃ ពីព្រោះគេរំពឹងថាធនាគារកណ្តាលUS នឹងឈប់តំលើងអត្រាការប្រាក់ក្នុងពេលដ៏ខ្លីដោយសារការបារម្ភថា កំនើនឱនភាពគណនីចរន្តUS អាចប៉ះពាល់ដល់តំលៃដុល្លារ ។

In December 2005, the Singapore dollar rallied against the greenback and appreciated to 1.676 S$/US$ from 1.698 S$/US$ in November 2005. Meanwhile, the Thai baht traded at 41.12 baht/USD, showing no change from the month earlier. Most Asian currencies were strengthened on lingering expectations that the Federal Reserve would call off its rate hikes sooner rather than later and by the concern that the widening U.S current account deficit would hurt the dollar.

## Thai Baht and Singaporean Dollar Against the US Dollar




Note: Data are up to 26 Dec. 2005
Sources: The Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នាខែវិច្ឆិកា ថ្លៃអង្ករអន្តរជាតិថយចុះ ដោយទីផ្សារមានសកម្មភាពតិច ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) ចុះដល់ ១១៦,៤ ធៀបនឹងកំរិត ១១៩ នៅខែតុលា ( ចុះ២,៦ពិន្ទុ ) ។ ថ្លៃអង្ករនៅUS នៅនឹងត្រឹម ៣០៣ដុល្លារ/តោន ។ នៅថៃ វាចុះថ្លៃ ៣,៥% ក្នុងរយៈពេល១ខែ ដោយសារគ្មានអ្នកទិញថ្មីៗ ។ អង្ករ Thai 100%B លក់បាន ២៨២ដុល្លារ/តោន ធៀបនឹង ២៩២ដុល្លារ/តោននៅខែតុលា ។

In November, the world rice prices declined due to small market activities. The international price index (IPO) decreased by 2.6 points from the previous month of 119 points in October to 116.4 points in November. The rice prices in US held steady at US$303 per ton. In Thailand, prices weakened by 3.5 percent in one month due to a lack of new buyers. In November, the Thai 100%B was at US$ 282 per ton, down from US$ 292 per ton in October.

**International Prices Index and Export Rice Prices**
(US$/ton FOB)




Source: Osiriz/InfoArroz and InterRice.

នៅខែធ្នូ ថ្លៃសណ្តែកសៀង និងពោតកើនឡើង ដោយលក់បាន ២៣៨,៦ ដុល្លារ/តោន និង ១០២,៣៦ដុល្លារ/តោន រឺមានកំណើន ៣% និង ៧% រៀងគ្នា បើធៀបនឹងខែមុន ។ ទិន្នន័យថ្លៃប្រេងឆានៅខែវិច្ឆិកា និងធ្នូ មិនទាន់មានទេ ប៉ុន្តែគេមិនរំពឹងថា វាមានការប្រែប្រួលច្រើនឡើយ ។

In December, the price of soybeans and maize rose. Soybeans were sold at US$238.6 per ton in December, up from US$231.46 per ton in November. The price represented a 3 percent increase from last month and a 7 percent increase from the same month last year. The price of maize rose by 7 percent from US$95.67 per ton in November to US$ 102.36 per ton in December. The data on the price of palm oil in November and December is not yet available, but the price is not expected to change much.

**International Prices of Soybean, Maize and Palm Oil** (US$/ton FOB)




Source: Food and Agriculture Organisation (FAO)

នៅខែធ្នូ ប្រេងឆៅ និងសាំងបានឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃនៅខែធ្នូនៃប្រទេសសមាជិក OPEC គឺ ៥២,៦៦ដុល្លារ/ធុង រឺមានកំណើន ២% ធៀបនឹងខែមុន ។ សាំងធម្មតានៅ US Gulf Coast ឡើងថ្លៃ ៦% ដល់ ៤០,៥៦សេន/លីត្រ ធៀបនឹង ៣៨,០៩សេន/លីត្រកាលពីខែវិច្ឆិកា ។ ( ចូរសំគាល់ថា ថ្លៃប្រេងសាំងក្នុងខែវិច្ឆិកាដែលរាយការណ៏នៅលេខមុនខ្ពស់ជាង នៅពេលនេះ ពីព្រោះជាថ្លៃដែលគេគិតរហូតដល់ថ្ងៃ២៥ វិច្ឆិកា ) ។

In December, the prices of crude oil and gasoline increased. The OPEC countries spot price of crude oil in December was US$ 52.66 per barrel, a 2 percent increase from the previous month. The conventional regular gasoline in US Gulf Coast in December rose by 6 percent from the previous month, selling at 40.56 cents per litre against 38.09 cents per litre in November. (Please note: the price of gasoline in November reported in previous issue is much higher than this because the price was reported up to 25 November).

**Prices of Crude Oil and Gasoline**




***Note: Data are up to 29 December** 2005*
*Sources: Energy Information Administration*

# ព័ត៌មានសេដ្ឋកិច្ច
# Economic News

**កូរ៉េខាងត្បូង និងអាស៊ាន ចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី:** កូរ៉េខាងត្បូង ចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយសមាជិកអាស៊ានទាំង ១០ប្រទេសនៅថ្ងៃ១៤ ធ្នូ ក្នុងមហាសន្និបាតអាស៊ាននៅកូឡាឡាំពួរ ។ "កិច្ចព្រមព្រៀងក្របខ័ណ្ឌ" នេះ គឺជារចនាសម្ព័ន្ធមូលដ្ឋាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ដែលនឹងបង្កើតទីផ្សារមួយមានមនុស្ស ៥៤៨លាននាក់ និងមានសេដ្ឋកិច្ចសរុបជាង ១,៤លានលានដុល្លារ ។ កូរ៉េខាងត្បូង និងអាស៊ានចរចាគ្នាយ៉ាងសកម្មតាំងពីឆ្នាំមុន ដើម្បីធ្វើFTA ឱ្យបានឆាប់ ក្នុងគោលដៅឱ្យមានការព្រមព្រៀងគ្នាស្តីពីទំនិញ នៅឆមាសទី១ ឆ្នាំក្រោយ ។

***S. Korea, ASEAN Sign Accord for Free Trade:*** South Korea signed a pact on free trade with the 10-member Association of Southeast Asian Nations (ASEAN) on Tuesday 14 December at the ASEAN summit in Kuala Lumpur. The ``framework agreement'' forms the basic structure of a free trade agreement (FTA), which will create a market of 548 million people with a combined economy of more than $1.4 trillion. South Korea and the ASEAN have engaged in intense negotiations for an early conclusion of the FTA since last year with the aim of striking a deal on goods in the first half of next year. *(Cited from The Korea Times 12/13/2005)*

**IMF លុបចោលបំណុល ៨២លានដុល្លាររបស់កម្ពុជា:** មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) លុបចោលបំណុល ៨២លានដុល្លារ ជំពាក់ដោយកម្ពុជា ដែលកំពុងព្យាយាមស្តារសេដ្ឋកិច្ច ក្រោយពីមានសង្គ្រាមអស់ជាច្រើនទសវត្សរ៍ ។ នេះការលុបចោល ១00% នៃប្រាក់ដែល IMF ឱ្យកម្ពុជាខ្ចីរហូតដល់ថ្ងៃ 0១ មករា ២00៥ ។ កម្ពុជាស្ថិតក្នុងចំណោម ១៩ប្រទេសដែលត្រូវបានជ្រើសរើសសំរាប់កញ្ចប់លុបចោលបំណុល ៣,៣ពាន់លានដុល្លារ អនុម័តដោយ IMF ។ សហគមន៏អ្នកផ្តល់ជំនួយ មានទាំង IMF ផង បានផ្តល់ជំនួយរាប់រយលានដុល្លារ ឱ្យកម្ពុជាក្នុងមួយឆ្នាំៗ ប៉ុន្តែក៏បានក្រើនរំលឹករដ្ឋាភិបាលពីផលប៉ះពាល់ដល់ការអភិវឌ្ឍន៏នៃអំពើពុករលួយរីករាលដាលពាសពេញ ។

***IMF Writes Off $82M in Debt for Cambodia:*** The International Monetary Fund is writing off $82 million owed by Cambodia, which is struggling to revive its economy after decades of armed conflict. The move amounts to 100 percent relief of all money lent to Cambodia by the IMF up until January 1, 2005. Cambodia is one of 19 countries chosen to benefit from a $3.3 billion debt relief package approved by the IMF. The donor community, including the IMF, has provided Cambodia with hundreds of millions of dollars in aid every year but also has warned the government about the impact of rampant corruption on development. *(Cited from AP 12/25/2005)*

**កម្ពុជាអនុម័តថវិកាសំរាប់ឆ្នាំ ២00៦:** នៅថ្ងៃ២៣ ធ្នូ រដ្ឋសភាកម្ពុជាបានអនុម័តថវិកា ៩២៦លានដុល្លារសំរាប់២00៦ ។ ថវិកានេះ ដែលមានទំហំ ២0% ច្រើនជាងចំណាយឆ្នាំ២00៥ ត្រូវបានអនុម័តដោយ ៨៤សំលេងទល់នឹង ១២សំលេង ។ ថវិកានេះរួមមាន ៦៨៣លានដុល្លារជាចំនូលពន្ធ និង ២៤៣ លានដុល្លារជាជំនួយ និងកំចី ។ រដ្ឋមន្ត្រីហិរញ្ញវត្ថុ គាត ឈុន បានជំរាបជូនអង្គប្រជុំសភា ពីផែនការបង្កើនចំណាយខាងធារាសាស្ត្រនៅឆ្នាំ២00៦ ដោយរដ្ឋាភិបាលនឹងផ្តល់ ២៥៥លានដុល្លារសំរាប់វិស័យនេះ និងពីការព្យាករណ៏កំនើនសេដ្ឋកិច្ច ៦,១% នៅឆ្នាំ២00៦ (៧% នៅឆ្នាំនេះ) ។

***Cambodia approves budget for 2006:*** Cambodia's National Assembly on December 23 endorsed a budget of 926 million USD for 2006. The budget, 20 percent higher than the 772 million USD in expenditure for 2005, was passed by an assembly vote of 84 to 12. The budget will include 683 million USD to be raised in tax revenue and 243 million USD in the form of grants and loans. Addressing the National Assembly session, Finance Minister Keat Chhon outlined plans to increase spending on irrigation in the 2006 budget. He said the government will have 255 million USD for irrigation. His Excellency Keat Chhon said Cambodia will have a 6.1 percent economic growth in 2006, less than this year's 7 percent *(Cited from VNA 12/24/2005)*

**ធនាគារពិភពលោកនឹងផ្តល់ ៣៦លានដុល្លារឱ្យកម្ពុជា:** ក្នុងជំនួបនាពេលថ្មីៗជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, លោក Ian Porter នាយកធនាគារពិភពលោកប្រចាំនៅកម្ពុជា បានបញ្ជាក់ថា ធនាគារពិភពលោកបានសំរេចផ្តល់ជំនួយឥតសំណង ៣៦លានដុល្លារ ជួយដល់កម្មវិធីកំណែទំរង់របស់កម្ពុជា ។ ក្នុងនេះ ១0លានដុល្លារ ត្រូវបានបែងចែកឱ្យទៅគំរោងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស ហើយជំនួយហិរញ្ញវត្ថុនេះ នឹងអាចបង្កើនថែមទៀត ដោយ យោងទៅតាមការជោគជ័យទទួលបានក្នុងដំណើរការកែទំរង់ ។

***WB to provide Cambodia with 36 million USD:*** The World Bank has decided to provide Cambodia with 36 million USD in non-refundable aid to help the country's reform programme, said Ian Porter, WB President in Cambodia, during his recent meeting in Phnom Penh with Prime Minister Hun Sen. An amount of 10 million USD would be soon allocated to support poverty reduction projects in the country, he said, adding that such financial assistance would be increased depending on the achievements obtained in the reform progress. *(Cited from VNA 12/29/2005)*